ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ១៥២ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើស និស្សិត និងមន្ត្រីរាជការទូទៅ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទេសចរណ៍សម្រាប់ឆ្នាំ២០១៧

**យោង** : លិខិតលេខ ៤៨៧ មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងទេសចរណ៍ សូមជម្រាបជូនដំណឹងដល់និស្សិត និងមន្ត្រីរាជការស៊ីវិលទូទៅ ឱ្យបានជ្រាបថា ក្រសួងទេសចរណ៍នឹងរៀបចំប្រឡងប្រជែងជ្រើសរើសនិស្សិត និងមន្ត្រីរាជការទូទៅ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងទេសចរណ៍សម្រាប់ឆ្នាំ២០១៧ ក្នុងប្រភេទក្របខណ្ឌ **ក** ចំនួន **៣៩កន្លែង** លើមុខជំនាញមានដូចជា: **ទេសចរណ៍, អក្សរសាស្ត្រអង់គ្លេស, នីតិសាស្ត្រ, គ្រប់គ្រង ,វិទ្យាសាស្ត្រកុំព្យូទ័រ, ភាសាបរទេសផ្សេងៗ និងមុខជំនាញដែលមានឧបនិស្ស័យទេសចរណ៍** មានដូចខាងក្រោម៖

I. **ទីស្តីការក្រសួងទេសចរណ៍ ជ្រើសរើសចំនួន ១៤ កន្លែង**

II. **មន្ទីរទេសចរណ៍រាជធានី ខេត្ត ជ្រើសរើសចំនួន ២៥ កន្លែង**

| | |
|---|---|
| ១-មន្ទីរទេសចរណ៍រាជធានីភ្នំពេញ | ចំនួន ០២ កន្លែង |
| ២-មន្ទីរទេសចរណ៍ខេត្តកណ្តាល | ចំនួន ០១ កន្លែង |
| ៣-មន្ទីរទេសចរណ៍ខេត្តតាកែវ | ចំនួន ០២ កន្លែង |
| ៤-មន្ទីរទេសចរណ៍ខេត្តកំពត | ចំនួន ០១ កន្លែង |
| ៥-មន្ទីរទេសចរណ៍ខេត្តកែប | ចំនួន ០១ កន្លែង |
| ៦-មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ | ចំនួន ០២ កន្លែង |
| ៧-មន្ទីរទេសចរណ៍ខេត្តកោះកុង | ចំនួន ០១ កន្លែង |
| ៨-មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ | ចំនួន ០១ កន្លែង |
| ៩-មន្ទីរទេសចរណ៍ខេត្តកំពង់ធំ | ចំនួន ០១ កន្លែង |
| ១០-មន្ទីរទេសចរណ៍ខេត្តកំពង់ចាម | ចំនួន ០២ កន្លែង |
| ១១-មន្ទីរទេសចរណ៍ខេត្តត្បូងឃ្មុំ | ចំនួន ០២ កន្លែង |
| ១២-មន្ទីរទេសចរណ៍ខេត្តក្រចេះ | ចំនួន ០២ កន្លែង |
| ១៣-មន្ទីរទេសចរណ៍ខេត្តរតនគិរី | ចំនួន ០១ កន្លែង |

១៤-មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី ចំនួន ០១ កន្លែង
១៥-មន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង ចំនួន ០១ កន្លែង
១៦-មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង ចំនួន ០១ កន្លែង
១៧-មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ចំនួន ០២ កន្លែង
១៨-មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ ចំនួន ០១ កន្លែង

**ក.លក្ខខណ្ឌនៃការជ្រើសរើស**

-មានសញ្ជាតិខ្មែរ

-លក្ខខណ្ឌអាយុ៖

- បេក្ខជនមានសញ្ញាបត្រថ្នាក់**បរិញ្ញាបត្រ** ត្រូវមានអាយុមិនលើសពី **៣៥ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)
- បេក្ខជនមានសញ្ញាបត្រថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់** ត្រូវមានអាយុមិនលើសពី **៤០ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)
- ត្រូវបានលើកលែងលក្ខខណ្ឌអាយុចំពោះបេក្ខជនដែលមានសញ្ញាបត្រថ្នាក់**បណ្ឌិត**ឡើងទៅ

-បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្ត

-បេក្ខជនជាមន្ត្រីរាជការទូទៅ ត្រូវមានលិខិតអនុញ្ញាតពីប្រធានក្រសួង ឬស្ថាប័ន

-ក្នុងករណីពិនិត្យឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជនប្រឡងជាប់ក៏ដោយ។

**ខ.កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំប្រឡង**

-**កាលបរិច្ឆេទលក់ និងទទួលពាក្យ៖** ចាប់ពី**ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧** នេះតទៅ រៀងរាល់ថ្ងៃពេលម៉ោងធ្វើការ

-**កាលបរិច្ឆេទឈប់ទទួលពាក្យ៖ ថ្ងៃសៅរ៍ទី១៥ ខែកក្កដា ឆ្នាំ២០១៧**

-បេក្ខជនត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងដោយផ្ទាល់ខ្លួន នៅទីស្តីការក្រសួងទេសចរណ៍ ដែលមានអាសយដ្ឋាន៖ **ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ** (**នាយកដ្ឋានធនធានមនុស្ស**) និងនៅ**មន្ទីរទេសចរណ៍រាជធានី ខេត្ត**

-បេក្ខជនដែលមានបំណងដាក់ពាក្យទៅបម្រើការងារនៅមន្ទីរទេសចរណ៍រាជធានីខេត្តត្រូវមានទីលំនៅបច្ចុប្បន្នស្ថិតនៅក្នុងរាជធានី ខេត្តនោះ **ដោយមានការបញ្ជាក់ពីប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត** លើពាក្យសុំចុះឈ្មោះប្រឡងជាកំណត់។

**គ.វិញ្ញាសាប្រឡង**

-ចំណេះដឹងទូទៅពាក់ព័ន្ធនឹងវិស័យទេសចរណ៍ (រយៈពេល **០២ ម៉ោង**)

-ភាសាអង់គ្លេស (រយៈពេល **០១ ម៉ោង៣០នាទី**)

**ឃ.កាលបរិច្ឆេទ និងមណ្ឌលប្រឡង**

-កាលបរិច្ឆេទប្រឡង៖ **ថ្ងៃអាទិត្យ ទី៣០ ខែកក្កដា ឆ្នាំ២០១៧**

-មណ្ឌលប្រឡង៖ **វិទ្យាល័យបាក់ទូក** អាសយដ្ឋាន៖ ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ

**ខ.សំណុំលិខិតក្នុងការដាក់ពាក្យប្រឡងរួមមាន**

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២. ជីវប្រវត្តិសង្ខេបមានបិទរូបថតថ្មី (៤ គុណ ៦) | ចំនួន ០១ច្បាប់ |
| ៣. សេចក្តីចម្លងសញ្ញាបត្រ | ចំនួន ០១ច្បាប់ |
| ៤. កិច្ចសន្យាបម្រើការងារ | ចំនួន ០១ច្បាប់ |
| ៥. សាលាកបត្រឯកត្តជន | ចំនួន ០១ច្បាប់ |
| ៦. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០១ច្បាប់ |
| ៧. សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| ៨. សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន ០១ច្បាប់ |
| ៩. លិខិតអនុញ្ញាតរបស់ប្រធានក្រសួង ស្ថាប័ន (**សម្រាប់បេក្ខជនជាមន្ត្រីរាជការ**) | ចំនួន ០១ច្បាប់ |
| ១០.លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |
| ១១.លិខិតបញ្ជាក់សុខភាព (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |

រាល់លិខិតស្នាមពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយខាងលើ ត្រូវមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ។

ចំពោះព័ត៌មានលម្អិតផ្សេងទៀត បេក្ខជនអាចសាកសួរនៅ**នាយកដ្ឋានធនធានមនុស្ស** នៃក្រសួងទេសចរណ៍រៀងរាល់ម៉ោងធ្វើការ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ៖ **០១២ ៥៩៥ ៦៦៦, ០៨៦ ៦២២ ៦៩០, ០១៧ ៥០៨ ៧៩៧** និងមន្ទីរទេសចរណ៍រាជធានី ខេត្ត។

**✳កំណត់សម្គាល់៖ សូមរក្សាសិទ្ធិកែប្រែសេចក្តីជូនដំណឹងនេះ ក្នុងករណីចាំបាច់។**

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- "ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ